ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែករបស់ធនាគារនេះ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០។

ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែករបស់ធនាគារត្រូវបានត្រួតពិនិត្យ ប៉ុន្តែមិនត្រូវបានធ្វើសវនកម្មទេ។

## ២. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុ

ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែករបស់ធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ នេះ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ៣៤ ស្តីពី "របាយការណ៍ហិរញ្ញវត្ថុសង្ខេប" (CIAS 34)។

ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែកនេះមិនរួមបញ្ចូលនូវកំណត់សម្គាល់ទាំងអស់ ដែលត្រូវបានបង្ហាញជាទូទៅនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរួម និងដោយឡែករបស់ធនាគារ ដែលបានធ្វើសវនកម្មទេ។ ដូចនេះ របាយការណ៍នេះគួរត្រូវបានអានភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរួម និងដោយឡែក ដែលបានធ្វើសវនកម្ម សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃ កម្ពុជា (CIFRS)។

គោលការណ៍គណនេយ្យដែលបានអនុវត្ត មានសង្គតិភាពជាមួយនឹងគោលការណ៍គណនេយ្យក្នុងឆ្នាំហិរញ្ញវត្ថុមុន និងគោលការណ៍គណនេយ្យក្នុងការិយបរិច្ឆេទមុន ដែលពាក់ព័ន្ធ។

ព័ត៌មានប្រៀបធៀបសម្រាប់របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបរួម និងដោយឡែករបស់ធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ និង៦ខែ របាយការណ៍បម្រែបម្រួលមូលធនសង្ខេបរួម និងដោយឡែក និងលំហូរសាច់ប្រាក់សង្ខេបរួម និងដោយឡែករបស់ធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ព្រមទាំងកំណត់សម្គាល់ពន្យល់ផ្សេងៗ សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មិនត្រូវបានធ្វើសវនកម្ម ឬ ត្រួតពិនិត្យទេ។

### ស្តង់ដារគណនេយ្យថ្មី និងវិសោធនកម្ម ដែលក្រុមហ៊ុនរួម និងធនាគារបានអនុវត្ត

មានស្តង់ដារគណនេយ្យថ្មី ឬវិសោធនកម្មមួយចំនួន បានចូលជាធរមានសម្រាប់ការិយបរិច្ឆេទរាយការណ៍នេះ។ ក្រុមហ៊ុនរួម និងធនាគារ មិនបានផ្លាស់ប្តូរគោលការណ៍គណនេយ្យរបស់ខ្លួន ឬ ធ្វើនិយ័តកម្មត្រឡប់ក្រោយ ដោយសារការអនុវត្តស្តង់ដារទាំងនោះទេ។

## ២. មូលដ្ឋាននៃការរៀបចំព័ត៌មានហិរញ្ញវត្ថុ (ត)

### ស្តង់ដារគណនេយ្យថ្មី និងវិសោធនកម្ម ដែលក្រុមហ៊ុនរួម និងធនាគារបានអនុវត្ត (ត)

COVID-19 ពាក់ព័ន្ធនឹងសម្បទានជួល – វិសោធនកម្ម CIFRS 16

ជាលទ្ធផលនៃការរាតត្បាតជម្ងឺCOVID-19 ការផ្តល់សម្បទានជួលត្រូវបានផ្តល់ទៅឱ្យភាគីអ្នកជួល។ សម្បទានបែបនេះ អាចមានទម្រង់ផ្សេងៗគ្នា រួមមានការផ្អាកការទូទាត់បណ្តោះអាសន្ន និងការពន្យារពេលទូទាត់ភតិសន្យា។ ក្នុងខែឧសភា ឆ្នាំ២០២០ IASB ត្រូវបានធ្វើវិសោធនកម្ម CIFRS 16 ស្តីពី ភតិសន្យាដែលផ្តល់ឱ្យភាគីអ្នកជួលនូវជម្រើសក្នុងការចាត់ទុកសម្បទានជួលដែលបំពេញលក្ខខ័ណ្ឌ តាមរបៀបដូចគ្នានឹងប្រតិបត្តិការដែលមិនមានការកែប្រែភតិសន្យា។ មានករណីជាច្រើន វានឹងធ្វើឱ្យសម្បទានជួល ជាការទូទាត់ប្រែប្រួលនៃភតិសន្យា ក្នុងអំឡុងពេលដែលពេលដែលសម្បទាននោះត្រូវបានផ្តល់ឱ្យ។

អង្គភាពដែលបានអនុវត្តជម្រើសងាយស្រួលនេះត្រូវតែបង្ហាញពីពត៌មាននេះ ថាតើជម្រើសនេះត្រូវបានអនុវត្តសម្រាប់សម្បទានជួលដែលបំពេញលក្ខខ័ណ្ឌទាំងអស់ ឬ បើមិនដូច្នោះទេ ត្រូវប្រាប់ពីព័ត៌មាននៃប្រភេទនៃកិច្ចសន្យាដែលត្រូវបានអនុវត្ត ក៏ដូចជាចំនួនទឹកប្រាក់ដែលបានកត់ត្រាក្នុងចំណេញ-ខាត ដែលកើតឡើងពីសម្បទានជួល។

ធនាគារមិនមានសម្បទានជួលណាមួយក្នុងអំឡុងការិយបរិច្ឆេទ ដូច្នេះ វិសោធនកម្មនេះមិនមានផលប៉ះពាល់លើព័ត៌មានហិរញ្ញវត្ថុរួម និងដោយឡែកឡើយ។

### ការបង្ហាញជាប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម របាយការណ៍ហិរញ្ញវត្ថុសង្ខេបរួមរបស់ក្រុមហ៊ុនរួម និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបដោយឡែករបស់ធនាគារត្រូវបង្ហាញជាប្រាក់រៀល។ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗរួម និងដោយឡែក និងលំហូរសាច់ប្រាក់រួម និងដោយឡែក ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាមធ្យមប្រចាំការិយបរិច្ឆេទ។ ទ្រព្យសកម្ម និងបំណុលដែលបានដាក់បង្ហាញក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដោយឡែកនីមួយៗ ត្រូវបានប្តូរដោយប្រើអត្រាថ្ងៃបិទបញ្ជី នាកាលបរិច្ឆេទរាយការណ៍។ លម្អៀងពីការប្តូរមូលធនភាគទុនិកត្រូវបានកត់ត្រាផ្ទាល់ក្នុងមូលធន ហើយរាល់លម្អៀងពីការប្តូរផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាក្នុងលទ្ធផលលម្អិតផ្សេងៗ។

គិតត្រឹមកាលបរិច្ឆេទរាយការណ៍ អត្រាមធ្យម និង អត្រាថ្ងៃបិទបញ្ជី គឺផ្អែកលើអត្រាប្តូរប្រាក់ដូចខាងក្រោមគឺ ១ដុល្លារអាមេរិក ស្មើនឹង៖

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ** | | **សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ** | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០** | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០** | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** |
| អត្រាមធ្យម | ៤.០៨៧ រៀល | ៤.០៥៣ រៀល | ៤.០៧៦ រៀល | ៤.០៣០ រៀល |

| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០** | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩** |
|---|---|---|
| អត្រាបិទបញ្ជី | ៤.០៩៣ រៀល | ៤.០៧៥ រៀល |

## ៣. ព្រឹត្តិការណ៍ និងប្រតិបត្តិការសំខាន់ៗ ក្នុងការិយបរិច្ឆេទរាយការណ៍នេះ

ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ ត្រូវបានរងផលប៉ះពាល់ជាពិសេស ដោយព្រឹត្តិការណ៍ និងប្រតិបត្តិការ ក្នុងអំឡុងការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ មានដូចខាងក្រោមៈ

*ការរាតត្បាតនៃជំងឺ COVID-19*

វីរុស novel coronavirus (COVID-19) ដែលត្រូវបានប្រកាសថាជាជំងឺឆ្លងរាតត្បាតពេញពិភពលោក បានឆ្លងរាលដាលមកដល់ប្រទេសកម្ពុជានៅចុងខែមករា ឆ្នាំ២០២០។ ចាប់តាំងពីពេលនោះមក ប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងហានិភ័យជាបន្តបន្ទាប់នៃការរីករាលដាលថ្នាក់ជាតិនៃវីរុសនេះបន្ថែមទៀត ដែលកំពុងបណ្តាលឱ្យមានការរាំងស្ទះដល់សកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ទោះបីជាយ៉ាងណាក៏ដោយ គណៈគ្រប់គ្រងយល់ឃើញថា សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនរួម និងធនាគារ អាចមានការថមថយក្នុងរយៈពេលខ្លី ប៉ុន្តែនឹងមិនបណ្តាលឱ្យក្រុមហ៊ុនមានបញ្ហាផ្នែកនិរន្តរភាពអាជីវកម្មទេ ដោយយោងទៅតាមទំហំនៃប្រតិបត្តិការ កម្រិតនៃប្រាក់ចំណេញនាពេលបច្ចុប្បន្ន និងទំហំសាច់ប្រាក់ងាយស្រួលរបស់ក្រុមហ៊ុនរួម និងធនាគារ។

*ការកែប្រែកតិសន្យា*

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ក្រុមហ៊ុន ជេ & អេ (ខេមបូឌា) អ៊ិនវេសមិន ឯ.ក (ហៅកាត់ថា "ក្រុមហ៊ុនបុត្រសម្ព័ន្ធ") ជាភាគីម្ចាស់ជួលបានធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងជួលជាមួយធនាគារជាភាគីអ្នកជួល ដើម្បីដំឡើងថ្លៃជួលសម្រាប់រយៈពេលដែលនៅសល់។ ដូច្នេះ ធនាគារត្រូវធ្វើការវាស់វែងឡើងវិញលើបំណុលភតិសន្យា និងទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់មិនផ្លាស់ប្តូរនៅថ្ងៃចាប់អនុវត្តការកែប្រែថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ (សូមមើលកំណត់សម្គាល់ ៧)។

*ការចេញផ្សាយសញ្ញាបណ្ណ*

ក្នុងអំឡុងការិយបរិច្ឆេទ ធនាគារបានចុះបញ្ជីសញ្ញាបណ្ណអាជីវកម្មក្នុងទីផ្សារមូលបត្រកម្ពុជា មានទឹកប្រាក់ចំនួន ៤០.០០០ លានរៀល ក្នុងដំណាក់កាលដំបូងនៃដំណើរការចេញផ្សាយសញ្ញាបណ្ណ ដែលត្រូវបានជាវទាំងស្រុង (សូមមើលកំណត់សម្គាល់ ៨)។ ធនាគារមានគម្រោងនឹងបង្កើនសញ្ញាបណ្ណអាជីវកម្ម ៤០.០០០ លានរៀល បន្ថែមទៀតនៅក្នុងដំណាក់កាលទី២របស់ខ្លួនក្នុងរយៈពេល៦ខែបន្ទាប់។

*ការបំលែងចំណេញរក្សាទុកទៅជាដើមទុន*

នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ ធនាគារបានផ្ទេរចំណេញរក្សាទុករបស់ខ្លួន មានទឹកប្រាក់ចំនួន ១២.០០០.០០០ ដុល្លារអាមេរិក ទៅជាដើមទុន ដែលត្រូវបានអនុម័តដោយធនាគារកណ្តាលនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ (សូមមើលកំណត់សម្គាល់ ៩)។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែក**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

## ៤. ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

ធនគារធ្វើការប៉ាន់ស្មាន និងការសន្មត ដោយគិតទៅលើអនាគត។ តាមនិយមន័យ លទ្ធផលនៃការប៉ាន់ស្មានកម្រស្មើគ្នាជាមួយនឹងលទ្ធផលជាក់ស្តែងណាស់។ ការប៉ាន់ស្មាន និងការសន្មត ដែលមានហានិភ័យជាសារវន្ត បណ្តាលឱ្យមាននិយ័តកម្មធំដុំចំពោះតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទរាយការណ៍បន្ទាប់ ត្រូវបានគូសបញ្ជាក់ដូចខាងក្រោម៖

ធនាគារវាយតម្លៃដោយឈរលើមូលដ្ឋានការខាតឥណទានរំពឹងទុកនាពេលអនាគត ("ECL") ដែលពាក់ព័ន្ធនឹងទ្រព្យសកម្មឧបករណ៍បំណុល វាស់វែងតាមថ្លៃដើមដករំលស់ និង FVOCI និងជាមួយផលប៉ះពាល់ដែលកើតមកពីកិច្ចសន្យាផ្តល់ឥណទាន (រួមមានឥណទានវិបារូបន៍ និងហ្វាស៊ីលីធីដែលអាចប្រើប្រាស់ឡើងវិញ) និងកិច្ចសន្យាធានាហិរញ្ញវត្ថុ ។ ការវាស់វែងសំវិធានធន ECL ឆ្លុះបញ្ចាំងពីព័ត៌មានដែលសមហេតុផល និងព័ត៌មានដែលមានការគាំទ្រ ដែលអាចស្វែងរកបាន ដោយមិនចាំបាច់ត្រូវមានការចំណាយ និងការប្រឹងប្រែងហួសប្រមាណ នាកាលបរិច្ឆេទរាយការណ៍អំពីព្រឹត្តិការណ៍ក្នុងអតីតកាល លក្ខខណ្ឌបច្ចុប្បន្ន និងការព្យាករអំពីលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត។ គណៈគ្រប់គ្រងបានកត់សម្គាល់អំពីផលប៉ះពាល់នៃជម្ងឺរាតត្បាត COVID-19 នៅក្នុងការវាយតម្លៃរបស់ខ្លួនចំពោះសំវិធានធន ECL នៃទ្រព្យសកម្មហិរញ្ញវត្ថុ រួមទាំងឥណទានដែលបានរៀបចំឡើងវិញ ដែលបណ្តាលមកពីផលប៉ះពាល់នៃការរាតត្បាតនៃជម្ងឺ COVID-19 ប៉ុន្តែគណៈគ្រប់គ្រងជឿជាក់ថា ការរាតត្បាតនៃជម្ងឺនេះ មិនមានផលប៉ះពាល់ជាសារវន្តដល់សំវិធានធននោះទេ ដូច្នេះមិនមាននិយ័តកម្មជាក់លាក់ណាមួយ ដោយសារផលប៉ះពាល់នៃការរាតត្បាតនៃជម្ងឺ ដែលត្រូវធ្វើសំវិធានធនសម្រាប់ការិយបរិច្ឆេទរាយការណ៍ទេ ពីព្រោះវារំពឹងថាការរាតត្បាតនៃជម្ងឺនេះនឹងមានរយៈពេលខ្លី ហើយនៅទីនោះមិនមានភស្តុតាងពីផលប៉ះពាល់ជាសារវន្តចំពោះសំវិធានធានECLនៃទ្រព្យសកម្មហិរញ្ញវត្ថុរហូតដល់កាលបរិច្ឆេទរាយការណ៍ឡើយ។

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យសំខាន់ៗផ្សេងទៀត ដែលគណៈគ្រប់គ្រងបានធ្វើឡើងក្នុងការអនុវត្តគោលការណ៍គណនេយ្យរបស់ក្រុមហ៊ុនរួម និងធនាគារ និងប្រភពសំខាន់ៗក្នុងការប៉ាន់ស្មានភាពមិនច្បាស់លាស់ គឺដូចគ្នាជាមួយនឹងការអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរួម និងដោយឡែក ដែលបានធ្វើសវនកម្មរួច សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដែរ។

## ៥. ប្រាក់ចំណូល និងព័ត៌មានតាមផ្នែក

ក្រុមហ៊ុនរួម និងធនាគារមានផ្នែកដែលត្រូវរាយការណ៍តែមួយគត់គឺ ចំណូលការប្រាក់។ ប្រធានដែលជាអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (ហៅកាត់ថា "ក្រុមគណៈគ្រប់គ្រង") ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលរាយការណ៍អំពីផ្នែកនៃចំណូលការប្រាក់ទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងបែងចែកធនធាន។ ក្រុមគណៈគ្រប់គ្រងក៏ត្រួតពិនិត្យអំពីប្រាក់ចំណេញមុនពន្ធ និងប្រាក់ចំណេញសុទ្ធទាំងមូល ធៀបនឹងការិយបរិច្ឆេទមុនៗផងដែរ។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែក**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

## ៦. ឥណទានអតិថិជន

### (ក) លម្អិតអំពីឥណទានអតិថិជនៈ

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានអតិថិជនតាមថ្លៃដើមដករំលស់ | ៦៨៩.០៩១.២៥៤ | ២.៨២០.៤៥០.៥០៣ | ៦៤៩.៧៧១.៤៤៩ | ២.៦៤៧.៨១៨.៦៥៥ | ៦៩៥.៣២៣.៦៧៩ | ២.៨៤៥.៩៥៩.៨១៨ | ៦៥៦.០០៣.៨៧៤ | ២.៦៧៣.២១៥.៧៨៧ |
| ដកៈ វិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក | (១.១៣៤.៥៧០) | (៤.៦៤៣.៧៩៥) | (១.០១៧.៦១៦) | (៤.១៤៦.៧៨៦) | (១.១៣៥.៩៨១) | (៤.៦៤៩.៥៧០) | (១.០១៧.៧០៧) | (៤.១៤៧.១៥៦) |
| **ឥណទានអតិថិជនសុទ្ធ** | ៦៨៧.៩៥៦.៦៨៤ | ២.៨១៥.៨០៦.៧០៨ | ៦៤៨.៧៥៣.៨៣៣ | ២.៦៤៣.៦៧១.៨៦៩ | ៦៩៤.១៨៧.៦៩៨ | ២.៨៤១.៣១០.២៤៨ | ៦៥៤.៩៨៦.១៦៧ | ២.៦៦៩.០៦៨.៦៣១ |

### (ខ) វិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ECL ១២ខែ (ដំណាក់កាលទី១) | ២៥៧.១៨៣ | ១.០៥២.៦៥០ | ២៨.៧០៦ | ១១៦.៩៧៧ | ២៥៨.៥៩៤ | ១.០៥៨.៤២៥ | ២៨.៧៩៧ | ១១៧.៣៤៧ |
| ECL ពេញមួយអាយុកាល -មិនមានការថយចុះតម្លៃឥណទាន (ដំណាក់កាលទី២) | ៧៤.៤៩៤ | ៣០៤.៩០៤ | ៥.៧៥៤ | ២៣.៤៤៨ | ៧៤.៤៩៤ | ៣០៤.៩០៤ | ៥.៧៥៤ | ២៣.៤៤៨ |
| Lifetime ECL - ការថយចុះតម្លៃឥណទាន (ដំណាក់កាលទី3) | ៨០២.៨៩៣ | ៣.២៨៦.២៤១ | ៩៨៣.១៥៦ | ៤.០០៦.៣៦១ | ៨០២.៨៩៣ | ៣.២៨៦.២៤១ | ៩៨៣.១៥៦ | ៤.០០៦.៣៦១ |
| | ១.១៣៤.៥៧០ | ៤.៦៤៣.៧៩៥ | ១.០១៧.៦១៦ | ៤.១៤៦.៧៨៦ | ១.១៣៥.៩៨១ | ៤.៦៤៩.៥៧០ | ១.០១៧.៧០៧ | ៤.១៤៧.១៥៦ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែក**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

## ៧. **ភតិសន្យា**

កំណត់សម្គាល់នេះផ្តល់នូវព័ត៌មានអំពីភតិសន្យា ដែលធនាគារគឺជាភាគីអ្នកជួល។

ក្រុមហ៊ុនរួម និងធនាគារបានជួលអគារមួយចំនួន សម្រាប់ធ្វើប្រតិបត្តិការរបស់ការិយាល័យកណ្តាល និងសាខា។ ជាទូទៅ កិច្ចសន្យាជួលត្រូវបានធ្វើឡើង សម្រាប់រយៈពេលកំណត់ចាប់ពី១ឆ្នាំ រហូតដល់២០ឆ្នាំ។

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ក្រុមហ៊ុន ជេ & អេ (ខេមបូឌា) អ៊ិនវេសមិ៊ន ឯ.ក (ហៅកាត់ថា "ក្រុមហ៊ុនបុត្រសម្ព័ន្ធ) គឺជាភាគីម្ចាស់ជួល បានធ្វើវិសោធនកម្មកិច្ចព្រមព្រៀងជួលរបស់ខ្លួនជាមួយធនាគារ ជាភាគីអ្នកជួល ដើម្បីដំឡើងថ្លៃឈ្នួល មានដូចខាងក្រោម៖

- ចាប់ពី ៤០.០០០ ដុល្លារអាមេរិក ទៅ ៦៩.០០០ ដុល្លារអាមេរិក ក្នុងមួយខែ ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និង
- ចាប់ពី ៦៩.០០០ ដុល្លារអាមេរិក ទៅ៨០.០០០ ដុល្លារអាមេរិក ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៩ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០៣១។

ធនាគារត្រូវធ្វើការវាស់វែងលើបំណុលភតិសន្យា និងទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់មិនផ្លាស់ប្តូរ នៅថ្ងៃចាប់អនុវត្តការកែប្រែដែលបានធ្វើឡើងនៅថ្ងៃទី០១ ខែឧសភាឆ្នាំ២០២០ ដោយបានប្រើអត្រាអប្បហារធ្វើការកែសម្រួលឡើងវិញ។

ចំពោះព័ត៌មានហិរញ្ញវត្ថុដោយឡែករបស់ធនាគារ ការកែប្រែកំណើនតម្លៃយោងនៃទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ដោយមានទឹកប្រាក់ចំនួន ៤.៧៨៤.៩០១ ដុល្លារអាមេរិក និងបំណុលភតិសន្យាមានទឹកប្រាក់ចំនួន ៤.១០៦.៤៣៦ ដុល្លារអាមេរិក ដើម្បីឆ្លុះបញ្ចាំងពីការកែប្រែនៃភតិសន្យា។

## ៧. គតិសន្យា (ត)

### (i) ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ (រយៈពេលវែង)* | | | | | | | | |
| ទីតាំងការិយាល័យ | ៨.០៩៥.៦៤៣ | ៣៣.១៣៥.៤៦៧ | ៥.៧៣១.៥១៩ | ២៣.៣៥៥.៩៤០ | ១៨.៣៦៥.៦០៨ | ៧៥.១៧០.៤៣៤ | ១១.៥២៧.៨៤១ | ៤៦.៩៧៥.៩៥២ |
| ទីតាំងទូATM | ១៦៥.៧៦៧ | ៦៧៨.៤៨៤ | ៦៩.៣១៤ | ២៨២.៤៥៥ | ១៦៥.៧៦៧ | ៦៧៨.៤៨៤ | ៦៩.៣១៤ | ២៨២.៤៥៥ |
| ក្តារបិទប្រកាស | ៨៩.២២៩ | ៣៦៥.២១៤ | ៣៧.៤២៨ | ១៥២.៥១៩ | ៨៩.២២៩ | ៣៦៥.២១៤ | ៣៧.៤២៨ | ១៥២.៥១៩ |
| ម៉ាស៊ីនភ្លើង | ៩១.៨០៣ | ៣៧៥.៧៥០ | ១១៦.៣៤១ | ៤៧៤.០៩០ | ៩១.៨០៣ | ៣៧៥.៧៥០ | ១១៦.៣៤១ | ៤៧៤.០៩០ |
| យានយន្ត | ៩៨.៤៧៦ | ៤០៣.០៦២ | ១២៣.៤៣៣ | ៥០២.៩៨៩ | ៩៨.៤៧៦ | ៤០៣.០៦២ | ១២៣.៤៣៣ | ៥០២.៩៨៩ |
| | ៨.៥៤០.៩១៨ | ៣៤.៩៥៧.៩៧៧ | ៦.០៧៨.០៣៥ | ២៤.៧៦៧.៩៩៣ | ១៨.៨១០.៨៨៣ | ៧៦.៩៩២.៩៤៤ | ១១.៨៧៤.៣៥៧ | ៤៨.៣៨៨.០០៥ |
| *បំណុលភតិសន្យា* | | | | | | | | |
| រយៈពេលខ្លី | ២.១០២.៦០៩ | ៨.៦០៥.៩៧៩ | ១.៧១០.៩៣៦ | ៦.៩៧២.០៦៦ | ២.១០២.៦០៩ | ៨.៦០៥.៩៧៨ | ២.១៩០.៩៣៦ | ៨.៩២៨.០៦៦ |
| រយៈពេលវែង | ៦.៧៥០.៣៣៧ | ២៧.៦២៩.១២៩ | ៥.០៣២.៨០៥ | ២០.៥០៨.៦៧៩ | ១៧.០៥៩.២៧៥ | ៦៩.៨២៣.៦១៣ | ១០.៩២១.៥១៥ | ៤៤.៥០៥.១៧២ |
| | ៨.៨៥២.៩៤៦ | ៣៦.២៣៥.១០៨ | ៦.៧៤៣.៧៤១ | ២៧.៤៨០.៧៤៥ | ១៩.១៦១.៨៨៤ | ៧៨.៤២៩.៥៩១ | ១៣.១១២.៤៥១ | ៥៣.៤៣៣.២៣៨ |

ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់បានបន្ថែមក្នុងអំឡុងការិយបរិច្ឆេទរបស់ក្រុមហ៊ុនរួម និងធនាគារ មានទឹកប្រាក់ចំនួន ៣.៣៣៦.៩៦២ ដុល្លារអាមេរិក (ឆ្នាំ២០១៩៖ ១.៣៩២.៧៧៣ ដុល្លារអាមេរិក)។

**៧.** **ភតិសន្យា** (ត)

(ii) **ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត**

របាយការណ៍ចំណេញ-ខាត បង្ហាញនូវចំនួនទឹកប្រាក់ដែលពាក់ព័ន្ធនឹងភតិសន្យា មានដូចខាងក្រោម៖

| | **ព័ត៌មានហិរញ្ញវត្ថុរួម** | | | | | | | |
|---|---|---|---|---|---|---|---|---|
| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ** | | | | **សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ** | | | |
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០** | | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០** | | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| | | | *មិនបានត្រួតពិនិត្យ* | *មិនបានត្រួតពិនិត្យ* | | | *មិនបានត្រួតពិនិត្យ* | *មិនបានត្រួតពិនិត្យ* |
| *រំលស់ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់* | | | | | | | | |
| ទីតាំងការិយាល័យ | ៣០០.៦៨៥ | ១.២២៥.៥៩២ | ២៥៨.០២២ | ១.០៣៩.៧០០ | ៤៥៣.១២០ | ១.៨៤៦.៩១៧ | ៥៦៥.៣៤៣ | ២.២៧៨.០៥០ |
| ទីតាំងទូATM | ២៩.៩៨១ | ១២២.២០១ | ១៧.១២៧ | ៦៩.០១៣ | ១៧.២៦៥ | ៧០.៣៧២ | ៣៨.២៣៨ | ១៥៤.០៨០ |
| ក្តារបិទប្រកាស | ៣២.១២១ | ១៣០.៩២៥ | ៤១.១៣៩ | ១៦៥.៧៧០ | ៨២.៦៣១ | ៣៣៦.៨០៤ | ៨៩.៣២៣ | ៣៥៩.៩២៧ |
| ម៉ាស៊ីនភ្លើង | ៣២.១២៧ | ១៣០.៩៥០ | ២៨.៧១៩ | ១១៥.៧២៣ | ៥៩.៧៧៣ | ២៤៣.៦៣៥ | ៥៧.៤៣៨ | ២៣១.៤៤៦ |
| យានយន្ត | ៣៥.១៤២ | ១៤៣.២៣៩ | ៣២.៣២២ | ១៣០.២៤១ | ៤៥.០៤៩ | ១៨៣.៦២០ | ៦៤.៦៤៤ | ២៦០.៤៨៣ |
| | ៤៣០.០៥៦ | ១.៧៥២.៩០៧ | ៣៧៧.៣២៩ | ១.៥២០.៤៤៧ | ៦៥៧.៨៣៨ | ២.៦៨១.៣៤៨ | ៨១៤.៩៨៦ | ៣.២៨៣.៩៨៦ |
| ចំណាយការប្រាក់ | ៦៨.៣៤៦ | ២៧៨.៥៨០ | ៤៧.៤៧៨ | ១៩១.៣១៣ | ១៥៩.៥១៦ | ៦៥០.១៨៧ | ១១០.៥៣៧ | ៤៤៥.៤០៩ |
| ចំណាយពាក់ព័ន្ធនឹងភតិសន្យា រយៈពេលខ្លី និងភតិសន្យាដែលមានតម្លៃទ្រព្យសកម្មទាប (ត្រូវបានរួមបញ្ចូលនៅក្នុងចំណាយប្រតិបត្តិការផ្សេងៗ) | ២០.០៥៣ | ៨១.៧៣៦ | ៥៦.២១៥ | ២២៦.៥២០ | ៤៣.២៣០ | ១៧៦.២០៥ | ៨៩.៣១៨ | ៣៥៩.៨០៦ |
| ចំណាយសរុបពាក់ព័ន្ធនឹងភតិសន្យា | ៨៨.៣៩៩ | ៣៦០.៣១៦ | ១០៣.៦៩៣ | ៤១៧.៨៣៣ | ២០២.៧៤៦ | ៨២៦.៣៩២ | ១៩៩.៨៥៥ | ៨០៥.៣១៥ |

លំហូរសាច់ប្រាក់ចេញសរុបរបស់ភតិសន្យាសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ មានទឹកប្រាក់ចំនួន ១.១៧១.០៣៣ ដុល្លាអាមេរិក (ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩៖ ៩៥៣.៩៥៥ ដុល្លារអាមេរិក)។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែក**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

## ៧. ភតិសន្យា (ត)

### (ii) ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត (ត)

| | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | | | | | |
|---|---|---|---|---|---|---|---|---|
| | សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ | | | | សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ | | | |
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | *មិនបានត្រួតពិនិត្យ* | *មិនបានត្រួតពិនិត្យ* | | | *មិនបានត្រួតពិនិត្យ* | *មិនបានត្រួតពិនិត្យ* |
| *រំលស់ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់* | | | | | | | | |
| ទីតាំងការិយាល័យ | ៥៥៧.២០០ | ២.២៧១.១៤៧ | ៣៩៥.៤៩៧ | ១.៥៩៣.៦៥៥ | ៧៦៤.៣៧៨ | ៣.១១៥.៦០៥ | ៧៥៨.៥៥៥ | ៣.០៥៦.៥៩៧ |
| ទីតាំងទូATM | ២៩.៩៨១ | ១២២.២០១ | ១៧.១២៧ | ៦៩.០១៣ | ១៧.២៦៥ | ៧០.៣៧២ | ៣៨.២៣៨ | ១៥៤.០៨០ |
| ក្ដារបិទប្រកាស | ៣២.១២១ | ១៣០.៩២៥ | ៤១.១៣៩ | ១៦៥.៧៧០ | ៨២.៦៣១ | ៣៣៦.៨០៤ | ៨៩.៣២៣ | ៣៥៩.៩២៧ |
| ម៉ាស៊ីនភ្លើង | ៣២.១២៧ | ១៣០.៩៥០ | ២៨.៧១៩ | ១១៥.៧២៣ | ៥៩.៧៧៣ | ២៤៣.៦៣៥ | ៥៧.៤៣៨ | ២៣១.៤៤៦ |
| យានយន្ត | ៣៥.១៤២ | ១៤៣.២៣៩ | ៣២.៣២២ | ១៣០.២៤១ | ៤៥.០៤៩ | ១៨៣.៦២០ | ៦៤.៦៤៤ | ២៦០.៤៨៣ |
| | ៦៨៦.៥៧១ | ២.៧៩៨.៤៦២ | ៥១៤.៨០៤ | ២.០៧៤.៤០២ | ៩៦៩.០៩៦ | ៣.៩៥០.០៣៦ | ១.០០៨.១៩៨ | ៤.០៦២.៥៣៣ |
| ចំណាយការប្រាក់ | ១៤៥.៣៩៥ | ៥៩២.៦៣២ | ១០២.២៧៨ | ៤១២.១២៩ | ១៥៩.៥១៦ | ៦៥០.១៨៧ | ២២១.៧៩៤ | ៨៩៣.៧១៩ |
| ចំណាយពាក់ព័ន្ធនឹងភតិសន្យា រយៈពេលខ្លី និងភតិសន្យាដែលមានតម្លៃទ្រព្យសកម្មទាប (ត្រូវបានរួមបញ្ចូលនៅក្នុងចំណាយប្រតិបត្តិការផ្សេងៗ) | ២០.០៥៣ | ៨១.៧៣៦ | ៥៦.២១៥ | ២២៦.៥២០ | ៤៣.២៣០ | ១៧៦.២០៥ | ៨៩.៣១៨ | ៣៥៩.៩០៦ |
| ចំណាយសរុបពាក់ព័ន្ធនឹងភតិសន្យា | ១៦៥.៤៤៨ | ៦៧៤.៣៦៨ | ១៥៨.៤៩៣ | ៦៣៨.៦៤៩ | ២០២.៧៤៦ | ៨២៦.៣៩២ | ៣១១.១១២ | ១.២៥៣.៦២៥ |

លំហូរសាច់ប្រាក់ចេញសរុបរបស់ភតិសន្យាសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ មានទឹកប្រាក់ចំនួន ១.៤៤៧.២៤០ ដុល្លារអាមេរិក (ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩៖ ១.០០៤.៤៩៤ ដុល្លារអាមេរិក)។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែក**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

## ៨. ការចេញផ្សាយមូលបត្របំណុល

ក្នុងឆ្នាំ២០១៩ ធនាគារបានស្នើសុំក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា "ផ.ម.ក")និង គណៈកម្មការមូលបត្រកម្ពុជា (ហៅកាត់ថា "គ.ម.ក") ដើម្បីចុះបញ្ជីសញ្ញាបណ្ណអាជីវកម្មរបស់ខ្លួន នៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ការស្នើសុំត្រូវបានអនុម័តជាគោលការណ៍ដោយក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ធនាគារបានទទួលការអនុម័តចុងក្រោយពីគណៈកម្មការមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីសញ្ញាបណ្ណអាជីវកម្មរបស់ខ្លួននៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនបានចេញផ្សាយមូលបត្របំណុលនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ ដែលមានតម្លៃជាទឹកប្រាក់ចំនួន ១០០.០០០ រៀល សរុប ៤០.០០០ លានរៀល ដែលមានរយៈពេលកំណត់៣ឆ្នាំ ដែលត្រូវបានជាវទាំងស្រុង។ សញ្ញាបណ្ណត្រូវបានចាត់ថ្នាក់ជាសញ្ញាបណ្ណដែលមានការការពារហានិភ័យការប្តូររូបិយប័ណ្ណ ដែលមានអត្រាគូប៉ុង៦,៥%ក្នុងមួយឆ្នាំ ដែលត្រូវបង់ការប្រាក់ជារៀងរាល់ឆមាស។

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេលខ្លី | ១៤៣.៨៦៦ | ៥៨៨.៨៤៣ | - | - | ១៤៣.៨៦៦ | ៥៨៨.៨៤៣ | - | - |
| រយៈពេលវែង | ៩.៧៣៤.៧២៩ | ៣៩.៨៤៤.២៤៦ | - | - | ៩.៧៣៤.៧២៩ | ៣៩.៨៤៤.២៤៦ | - | - |
| | ៩.៨៧៨.៥៩៥ | ៤០.៤៣៣.០៨៩ | - | - | ៩.៨៧៨.៥៩៥ | ៤០.៤៣៣.០៨៩ | - | - |

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទឹកប្រាក់ដើម | ៩.៧៣៤.៧២៩ | ៣៩.៨៤៤.២៤៦ | - | - | ៩.៧៣៤.៧២៩ | ៣៩.៨៤៤.២៤៦ | - | - |
| ការប្រាក់ត្រូវសង | ១៤៣.៨៦៦ | ៥៨៨.៨៤៣ | - | - | ១៤៣.៨៦៦ | ៥៨៨.៨៤៣ | - | - |
| | ៩.៨៧៨.៥៩៥ | ៤០.៤៣៣.០៨៩ | - | - | ៩.៨៧៨.៥៩៥ | ៤០.៤៣៣.០៨៩ | - | - |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែក**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

## ៩. ដើមទុន

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ធនាគារបានស្នើសុំឱ្យធនាគារកណ្តាលបង្កើនដើមទុនរបស់ខ្លួនពី ៨០.០០០.០០០ ដុល្លារអាមេរិក រហូតដល់ ៩២.០០០.០០០ ដុល្លារអាមេរិក ដោយបំលែងចំណេញរក្សាទុកមានទឹកប្រាក់ចំនួន ១២.០០០.០០០ ដុល្លារអាមេរិក ទៅជាដើមទុន ដែលត្រូវបានអនុម័តដោយធនាគារកណ្តាលនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាដើមការិយបរិច្ឆេទ | ៨០.០០០.០០០ | ៣២៦.០០០.០០០ | ៨០.០០០.០០០ | ៣២១.៤៤០.០០០ | ៨០.០០០.០០០ | ៣២៦.០០០.០០០ | ៨០.០០០.០០០ | ៣២១.៤៤០.០០០ |
| បំលែងចំណេញរក្សាទុកទៅជាដើមទុន | ១២.០០០.០០០ | ៤៨.៩១២.០០០ | - | - | ១២.០០០.០០០ | ៤៨.៩១២.០០០ | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ១.៦៤៤.០០០ | - | ៤.៥៦០.០០០ | - | ១.៦៤៤.០០០ | - | ៤.៥៦០.០០០ |
| នាដំណាច់ការិយបរិច្ឆេទ | ៩២.០០០.០០០ | ៣៧៦.៥៥៦.០០០ | ៨០.០០០.០០០ | ៣២៦.០០០.០០០ | ៩២.០០០.០០០ | ៣៧៦.៥៥៦.០០០ | ៨០.០០០.០០០ | ៣២៦.០០០.០០០ |

| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ | | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | |
|---|---|---|---|---|---|---|
| | ចំនួនភាគហ៊ុន | ភាគរយ | ដុល្លារអាមេរិក | ចំនួនភាគហ៊ុន | ភាគរយ | ដុល្លារអាមេរិក |
| **ភាគទុនិកៈ** | | | | | | |
| Jeonbuk Bank Co., Ltd | ៤៦.០០០ | ៥០% | ៤៦.០០០.០០០ | ៤០.០០០ | ៥០% | ៤០.០០០.០០០ |
| Apro Financial Co., Ltd | ៣៦.៨០០ | ៤០% | ៣៦.៨០០.០០០ | ៣២.០០០ | ៤០% | ៣២.០០០.០០០ |
| JB Woori Capital Co., Ltd | ៩.២០០ | ១០% | ៩.២០០.០០០ | ៨.០០០ | ១០% | ៨.០០០.០០០ |
| | | | ៩២.០០០.០០០ | | | ៨០.០០០.០០០ |
| *គិតជាពាន់រៀល* | | | ៣៧៦.៥៥៦.០០០ | | | ៣២៦.០០០.០០០ |

## ១១. ការវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ

កំណត់សម្គាល់នេះផ្តល់នូវបច្ចុប្បន្នកម្មអំពីការវិនិច្ឆ័យ និងការប៉ាន់ស្មានដែលក្រុមហ៊ុនរួម និងធនាគារបានធ្វើ ក្នុងការកំណត់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ ចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មចុងក្រោយបំផុតមក។

### (ក) ឋានានុក្រមនៃតម្លៃសមស្រប

ដើម្បីផ្តល់នូវសញ្ញាណអំពីភាពអាចទុកចិត្តបាន របស់ទិន្នន័យដែលបានប្រើប្រាស់ក្នុងការកំណត់តម្លៃសមស្របក្រុមហ៊ុនរួម និងធនាគារបានចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាបីកម្រិត ដូចបានពណ៌នាក្នុងស្តង់ដារគណនេយ្យ។ ការពន្យល់អំពីកម្រិតនីមួយៗ មានបង្ហាញនៅក្នុងតារាងខាងក្រោម។

តារាងខាងក្រោមនេះបង្ហាញពីទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារដែលត្រូវបានវាស់វែង និងត្រូវបានកត់ត្រាតាមតម្លៃសមស្រប នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ តាមមូលដ្ឋានដែលបានកើតឡើង៖

| | ព័ត៌មានហិរញ្ញវត្ថុរួម | | | |
|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២០** | **កម្រិត ១ ដុល្លារអាមេរិក** | **កម្រិត ២ ដុល្លារអាមេរិក** | **កម្រិត ៣ ដុល្លារអាមេរិក** | **សរុប ដុល្លារអាមេរិក** |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| *ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ (FVOCI)* | | | | |
| មូលបត្រកម្មសិទ្ធិ – សេវាសាធារណៈ | ១៦១.១១២ | - | ២១.៨១៨ | ១៨២.៩៣០ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ១៦១.១១២ | - | ២១.៨១៨ | ១៨២.៩៣០ |
| *គិតជាពាន់រៀល* | ៦៥៩.៤៣១ | - | ៨៩.៣០១ | ៧៤៨.៧៣២ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| *ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ (FVOCI)* | | | | |
| មូលបត្រកម្មសិទ្ធិ – សេវាសាធារណៈ | ១៨១.៩១៩ | - | ២១.៨១៨ | ២០៣.៧៣៧ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ១៨១.៩១៩ | - | ២១.៨១៨ | ២០៣.៧៣៧ |
| *គិតជាពាន់រៀល* | ៨៣០.២៣០ | - | ៨៨.៩០៨ | ៩១៩.១៣៨ |

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែក**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

**១១. ការវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ (ត)**
**(ក) ឋានានុក្រមនៃតម្លៃសមស្រប (ត)**

| | ព័ត៌មានហិរញ្ញវត្ថុដោយឡែក | | | |
|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២០** | **កម្រិត ១ ដុល្លារអាមេរិក** | **កម្រិត ២ ដុល្លារអាមេរិក** | **កម្រិត ៣ ដុល្លារអាមេរិក** | **សរុប ដុល្លារអាមេរិក** |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| *ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ (FVOCI)* | | | | |
| មូលបត្រកម្មសិទ្ធិ – សេវាសាធារណៈ | ១៦១.១១២ | - | ២១.៨១៨ | ១៨២.៩៣០ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ១៦១.១១២ | - | ២១.៨១៨ | ១៨២.៩៣០ |
| *គិតជាពាន់រៀល* | ៦៥៩.៤៣១ | - | ៨៩.៣០១ | ៧៤៨.៧៣២ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| *ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ (FVOCI)* | | | | |
| មូលបត្រកម្មសិទ្ធិ – សេវាសាធារណៈ | ១៨១.៩១៩ | - | ២១.៨១៨ | ២០៣.៧៣៧ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ១៨១.៩១៩ | - | ២១.៨១៨ | ២០៣.៧៣៧ |
| *គិតជាពាន់រៀល* | ៨៣០.២៣០ | - | ៨៨.៩០៨ | ៩១៩.១៣៨ |

**កម្រិត ១ ៖** តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានជួញដូរនៅក្នុងទីផ្សារសកម្ម (ដូចជា ឧបករណ៍និទស្សន៍ដែលបានជួញដូរជាសាធារណៈ និងមូលបត្រកម្មសិទ្ធិ) គឺអាស្រ័យទៅតាមតម្លៃដែលបានដាក់លក់លើទីផ្សារ នាដំណាច់ការិយបរិច្ឆេទរាយការណ៍។ តម្លៃដាក់លក់លើទីផ្សារដែលបានប្រើសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលក្រុមហ៊ុនបានកាន់កាប់ គឺជាតម្លៃទិញបច្ចុប្បន្ន។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងកម្រិត ១ ។

**កម្រិត ២ ៖** តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុដែលមិនត្រូវបានជួញដូរនៅក្នុងទីផ្សារសកម្ម (ឧទាហរណ៍ដូចជា ឧបករណ៍និទស្សន៍ over–the–counter) ត្រូវបានកំណត់ដោយប្រើវិធីសាស្ត្រវាយតម្លៃ ដែលបង្កើនការប្រើប្រាស់ទិន្នន័យលើទីផ្សារដែលអាចអង្កេតបាន និងបន្ថយការពឹងផ្អែកទៅលើការប៉ាន់ស្មានចំពោះអង្គភាពជាក់លាក់។ ប្រសិនបើទិន្នន័យជាក់លាក់ទាំងអស់ដែលតម្រូវសម្រាប់ឧបករណ៍មួយ អាចអង្កេតបាន ឧបករណ៍នោះត្រូវបានបញ្ចូលទៅក្នុងកម្រិត ២ ។

**កម្រិត ៣ ៖** ប្រសិនបើទិន្នន័យជាក់លាក់មួយឬច្រើន មិនពឹងផ្អែកទៅលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឧបករណ៍នោះត្រូវបានបញ្ចូលទៅក្នុងកម្រិត ៣ ។ វាគឺជាករណីសម្រាប់មូលបត្រកម្មសិទ្ធិដែលមិនបានចុះបញ្ជី។

**១១. ការវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ (ត)**

**(ខ) បច្ចេកទេសវាយតម្លៃត្រូវបានប្រើប្រាស់ដើម្បីកំណត់តម្លៃសមស្រប**

បច្ចេកទេសវាយតម្លៃត្រូវបានប្រើប្រាស់ដើម្បីកំណត់តម្លៃសមស្របរួមមាន ការប្រើប្រាស់ការវាយតម្លៃទីផ្សារដែលអាចមាននៅលើទីផ្សារមូលបត្រកម្ពុជា។

**(គ) ការវាស់វែងតម្លៃសមស្របដោយប្រើទិន្នន័យជាក់លាក់មិនអាចអង្កេតបាន (កម្រិត៣)**

មូលបត្រកម្មសិទ្ធិដែលមិនបានចុះបញ្ជី គឺការវិនិយោគនៅក្នុងការិយាល័យឥណទាននៃកម្ពុជា ("CBC") ដែលត្រូវវាស់វែងតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ ដោយសារវាមិនត្រូវបានកាន់កាប់ដើម្បីជួញដូរទេ ហើយក្រុមហ៊ុនបានសម្រេចជ្រើសរើសយកការកត់ត្រាលើកដំបូងរបស់វា ជាទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាម FVOCI។ នេះគឺជាការវិនិយោគជាយុទ្ធសាស្ត្រ ហើយក្រុមហ៊ុនចាត់ទុកថាការធ្វើចំណាត់ថ្នាក់បែបនេះ គឺមានភាពសមស្រប។

តម្លៃសមស្របត្រូវបានកំណត់ដោយផ្អែកទៅតាមតម្លៃបច្ចុប្បន្ន ហើយអត្រាអប្បហារដែលបានប្រើប្រាស់ ត្រូវបានកែតម្រូវទៅតាមហានិភ័យឥណទានរបស់ភាគីដៃគូ ឬហានិភ័យឥណទានរបស់ក្រុមហ៊ុនផ្ទាល់។ មិនមានការកត់ត្រាចំណេញ/ខាតនៅក្នុងលទ្ធផលលម្អិតផ្សេងៗទេ ដោយសារតម្លៃសមស្រប ប្រហាក់ប្រហែលនឹងតម្លៃយោង។ នៅថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០២០ មិនមានការកត់ត្រាសំវិធានធនបាត់បង់សម្រាប់ FVOCI នេះទេ។

**(ឃ) ឧបករណ៍ហិរញ្ញវត្ថុដែលមិនវាស់វែងតាមតម្លៃសមស្រប**

គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា។

ការប៉ាន់ស្មានតម្លៃសមស្របផ្អែកទៅតាមវិធីសាស្ត្រ និងការសន្មតដូចខាងក្រោម៖

(i) ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល និងធនាគារ

តម្លៃយោងនៃប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល និងធនាគារ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ដោយសារគណនីទាំងនេះភាគច្រើនគឺជាគណនីចរន្ត គណនីសន្សំ និងប្រាក់បញ្ញើរយៈពេលខ្លី។

(ii) ឥណទានអតិថិជន

ចំពោះឥណទានដែលមានអត្រាថេរ ដែលមានកាលកំណត់នៅសល់តិចជាង១ឆ្នាំ ជាទូទៅតម្លៃយោងរបស់វា គឺជាតម្លៃសមស្របប៉ាន់ស្មានរបស់វា។

ចំពោះឥណទានដែលមានអត្រាថេរ និងមានកាលកំណត់នៅសល់១ឆ្នាំ ឬលើសពី១ឆ្នាំ តម្លៃសមស្របត្រូវបានប៉ាន់ស្មានដោយធ្វើអប្បហារលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត និងប្រើអត្រាការប្រាក់របស់ឥណទាននាពេលបច្ចុប្បន្ន ដោយសារអត្រាការប្រាក់តាមទីផ្សាររបស់ឥណទាន មានហានិភ័យឥណទាន និងកាលកំណត់ប្រហាក់ប្រហែលគ្នា ហើយត្រូវបានវាយតម្លៃថាមានភាពខុសគ្នាតិចតួច ជាមួយនឹងអត្រាការប្រាក់របស់ឥណទានតាមកិច្ចសន្យា។ ជាលទ្ធផល តម្លៃសមស្របនៃឥណទាន និង បុរេប្រទានអតិថិជនរយៈពេលវែង អាចមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា នាកាលបរិច្ឆេទរាយការណ៍។

**កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួម និងដោយឡែក**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

**១១. ការវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុ (ត)**
**(ឃ) ឧបករណ៍ហិរញ្ញវត្ថុដែលមិនវាស់វែងតាមតម្លៃសមស្រប (ត)**

(iii) ប្រាក់បញ្ញើរបស់អតិថិជន

តម្លៃសមស្របនៃប្រាក់បញ្ញើរបស់អតិថិជន ដែលមានកាលកំណត់តិចជាង១ឆ្នាំ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា ដោយសារឧបករណ៍ទាំងនេះមានរយៈពេលខ្លី។ តម្លៃសមស្របនៃប្រាក់បញ្ញើរបស់អតិថិជន ដែលមានកាលកំណត់១ឆ្នាំ ឬច្រើនជាង ត្រូវបានគេរំពឹងថាមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា ដោយសារធនាគារបានផ្តល់អត្រាការប្រាក់ប្រហាក់ប្រហែលគ្នាជាមួយនឹងឧបករណ៍ដែលមានកាលកំណត់ និងលក្ខខណ្ឌឥណទានស្រដៀងគ្នាដែរ។

តម្លៃសមស្របប៉ាន់ស្មាន់នៃប្រាក់បញ្ញើរបស់អតិថិជន ដែលមិនមានកាលកំណត់ រួមមានប្រាក់បញ្ញើមិនមានការប្រាក់ ប្រាក់បញ្ញើត្រូវសងតាមតម្រូវការ គឺជាទឹកប្រាក់ត្រូវសងនាកាលបរិច្ឆេទរាយការណ៍។

(iv) ទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុផ្សេងៗ

តម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានសន្មតថាមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ដោយសារគណនីទាំងនេះមិនមានតម្លៃប្រែប្រួលជាសារវន្តទៅតាមអត្រាទីផ្សារទេ។

(v) ប្រាក់កម្ចី និងអនុបំណុល

ប្រាក់កម្ចី និងអនុបំណុល មិនត្រូវបានដាក់លក់លើទីផ្សារសកម្មទេ ហើយតម្លៃសមស្របរបស់វា ប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា។

(vi) មូលបត្របំណុល

ជាទូទៅ តម្លៃសមស្របប៉ាន់ស្មាននៃមូលបត្របំណុល គឺអាស្រ័យទៅតាមតម្លៃទីផ្សារដែលអាចអង្កេតបាន នាកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ វាមិនត្រូវបានជួញដូរយ៉ាងសកម្មទេ។ តម្លៃសមស្របប៉ាន់ស្មាននៃមូលបត្របំណុល គឺប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា ដោយផ្អែកទៅតាមលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដោយប្រើអត្រាលើទីផ្សារ។